**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

លេខ ០៩៤ ប៉ក.ក៣ស.

# ប្រកាស

## ស្តីពី

## ការជ្រើសរើសនិស្សិត សិស្សចូលបណ្តុះបណ្តាលជំនាញ បច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៧ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការពារជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៥ ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ
- បានឃើញអនុក្រឹត្យលេខ ៦៥ អនក្រ.បក ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ៣១ អនក្រ.បក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការកែសម្រួលរចនាសម្ព័ន្ធ និងប្តូរឈ្មោះខុទ្ទកាល័យ ក្រសួងការពារជាតិ មកជាអគ្គលេខាធិការដ្ឋាន ក្រសួងការពារជាតិ
- បានឃើញអនុក្រឹត្យលេខ ១២ អនក្រ.បក ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០១០ ស្តីពីការប្រែក្លាយសាលាជំនាញឯកទេសចម្រុះ ទៅជាវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន
- បានឃើញសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាលលេខ ៥៦ ស.ស.រ ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៧ ស្តីពីការជ្រើសរើសនិស្សិត សិស្សចូលបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន ជារៀងរាល់ឆ្នាំ
- យោងតាមសំណើរបស់ នាយក នាយកដ្ឋានបុគ្គលិក

## សម្រេច

**ប្រការ១.-**

ត្រូវបានប្រគល់ភារកិច្ចជូននាយកដ្ឋានបុគ្គលិក សហការជាមួយអគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស ជ្រើសរើសនិស្សិត សិស្សចូលបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធាកម្រិតបច្ចេកទេសបឋម នៅវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន ដែលមានសន្ទស្សន៍១២០(មួយរយម្ភៃ)នាក់ សម្រាប់ឆ្នាំសិក្សា២០២៣ ។

**ប្រការ២.-**

វិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន ត្រូវចាត់តាំងបើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសយោធា កម្រិតបច្ចេកទេសបឋម ចំនួន១២០នាក់ ដែលមានរយៈពេលសិក្សា១ឆ្នាំ ។

**ប្រការ៣.-**

បេក្ខជនទាំងពីរភេទត្រូវជ្រើសរើសពីចំណោមនិស្សិត សិស្សដែលស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌនៃកងយោធពលខេមរភូមិន្ទ ហើយត្រូវមានលក្ខណសម្បត្តិដូចតទៅ៖

ក- សញ្ជាតិខ្មែរ

ខ- មានអាយុពី ១៨ឆ្នាំ ដល់ ២៥ឆ្នាំ គិតត្រឹមថ្ងៃដាក់ពាក្យ

គ- មានកាយសម្បទាគ្រប់គ្រាន់តាមតម្រូវការ ដើម្បីបំពេញមុខងារ

ឃ- មិនធ្លាប់ត្រូវបានតុលាការផ្តន្ទាទោស

ង- មានសញ្ញាបត្រ មធ្យមសិក្សាទុតិយភូមិ ឡើងទៅ

ច- បុរសមានកម្ពស់ ១.៦០ម និងនារីមានកម្ពស់ ១.៥០ម ឡើងទៅ

បេក្ខជនទាំងពីរភេទត្រូវមកទំនាក់ទំនងដាក់ពាក្យសុំចុះឈ្មោះនៅនាយកដ្ឋានបុគ្គលិក ។

**ប្រការ៤ .-**

បេក្ខជនទាំងពីរភេទ ត្រូវគោរពឱ្យបានម៉ឺងម៉ាត់ តាមលក្ខខណ្ឌទាំងឡាយដែលមានចែង ក្នុងកិច្ចសន្យាស្ម័គ្រចិត្តចូលបម្រើការងារក្នុងក្របខ័ណ្ឌកងយោធពលខេមរភូមិន្ទ ។

**ប្រការ៥.-**

សិក្ខាកាមពេលចូលសិក្សាដំបូង ត្រូវទទួលបានបំពាក់ឋានន្តរសក្តិថ្នាក់ពលបាលត្រី និងដំឡើងឋានន្តរសក្តិជានាយចំណង់ ចំពោះកម្មសិក្សាការីដែលបានប្រឡងជាប់ជាស្ថាពរ ។ ដោយឡែក កម្មសិក្សាការីដែលប្រឡងធ្លាក់ មិនត្រូវបានដំឡើងឋានន្តរសក្តិឡើយ ។

**ប្រការ៦.-**

អគ្គលេខាធិការក្រសួងការពារជាតិ អគ្គនាយក អគ្គនាយកដ្ឋាន ភស្តុភារ-ហិរញ្ញវត្ថុ អគ្គនាយក អគ្គនាយកដ្ឋានសម្ភារៈបច្ចេកទេស នាយក នាយកដ្ឋានបុគ្គលិក នាយកវិទ្យាស្ថានបច្ចេកទេសយោធាតេជោ ហ៊ុន សែន និងមេបញ្ជាការកងឯកភាពដែលមានការពាក់ព័ន្ធត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ចន្ទ ១១ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ ៣ ឆ្នាំ ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

សម្តេចពិជ័យសេនា ទៀ-បាញ់

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងយុត្តិធម៌
- ក្រសួងអប់រំយុវជន និងកីឡា
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចពិជ័យសេនា ទៀ បាញ់
- ខុទ្ទកាល័យអគ្គបញ្ជាការដ្ឋាន ខ.ភ.ម
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ